## ១- ឈ្មោះ និង ការចាត់ថ្នាក់នៃប្រភេទឈើ

ឈ្មោះក្នុងស្រុក : ក្រញូង

ឈ្មោះវិទ្យាសាស្ត្រ : *Dalbergia cochinchinensis* **Pierre**

អំបូរ : **Leguminosae**

ចំណាត់ថ្នាក់ជាតិ : **ឈើប្រណីត**

## ២- ការរាយប៉ាយក្នុងធម្មជាតិ និង ទីកន្លែងដុះដាល

ដើមក្រញូងមានដើមកំណើតនៅបណ្តាប្រទេសឥណ្ឌូចិនដូចជា កម្ពុជា វៀតណាម ឡាវ ថៃ និងប្រទេសដែលនៅជិតខាង។ វាច្រើនដុះនៅក្នុងតំបន់ព្រៃដីទំនាបដែលមានរបបទឹកភ្លៀងប្រចាំឆ្នាំពី ១២០០-១៦៥០ម.ម ហើយមានសីតុណ្ហភាពប្រចាំឆ្នាំពី ២០-៣២អង្សាសេ និង មានសីតុណ្ហភាពទាបបំផុតត្រឹម១០អង្សាសេ។ ដើមក្រញូងត្រូវការសំណើមមធ្យម ចូលចិត្តពន្លឺថ្ងៃហើយធន់នឹងរដូវរាំងស្ងួតរយៈពេលយូរ។ ប្រភេទនេះមិនទាមទារលក្ខខណ្ឌដីល្អប៉ុន្មានទេ ប៉ុន្តែវាចូលចិត្តដុះនៅលើដីឥដ្ឋ ល្បាយខ្សាច់ និង ដីដែលមានជាតិកំបោរ។ ក្រញូងដុះលូតលាស់នៅក្នុងព្រៃល្បោះ និង ព្រៃពាក់កណ្តាលស្រោងហើយជារឿយៗគេជួបប្រទះប្រភេទនេះដុះជាជ្រុំៗ ប្រមូលផ្តុំច្រើននៅរយៈកំពស់ពី៤០០-៥០០ម ធៀបទៅនឹងនីវ៉ូសមុទ្រ។ តាមផែនទីរបាយដំណុះឈើអាទិភាពដែលរៀបចំដោយគំរោងគ្រាប់ពូជឈើកម្ពុជា គេសង្កេតឃើញថានៅប្រទេសកម្ពុជាក្រញូងមានដុះនៅក្នុងខេត្តមួយចំនួន ដូចជា: រតនគីរី ក្រចេះ មណ្ឌលគីរី ស្ទឹងត្រែង ព្រះវិហារ សៀមរាប កំពង់ធំ ពោធិ៍សាត់ និងកោះកុង។ នៅក្នុងខេត្តសៀមរាប គំរោងគ្រាប់ពូជឈើកម្ពុជាបានបង្កើតប្រភពគ្រាប់ពូជឈើក្រញូងក្នុងព្រៃធម្មជាតិមួយកន្លែង មានទីតាំងឋិតនៅក្នុងឃុំស្រែណូយ ស្រុកវ៉ារិន ដែលមានផ្ទៃដីទំហំ ៥០ហ.ត និង មានដើមមេដែលបានជ្រើសរើសសំរាប់បេះប្រមូលគ្រាប់ពូជចំនួន ១២១ដើម។

## ៣- ការប្រើប្រាស់

ក្រញូងជាប្រភេទឈើមានទំហំធំ ដែលអាចទាក់ទាញក្នុងការដាំដុះ។ សាច់ឈើមានសរសៃល្អណាស់ មានស្រាយពណ៌ប្រផេះព្រឿងៗ ខ្លឹមរឹង មានពណ៌ក្រហមត្នោតស្ទើរតែពណ៌ខ្មៅ សាច់ឈើហាប់ម៉ដ្ឋល្អ ជាប់រឹងធ្ងន់។ ប្រភេទនេះមានដង់ស៊ីតេស្មើនឹង ១,០៩ ងាយស្រួលកែច្នៃ ជាប់មាំ មិនប្រេះបែក នៅពេលស្ងួត ប្រើបានយូរ លើសពីនេះធន់នឹងពពួកសត្វល្អិត និង កណ្ដៀរ។ ដើមឈើមានទំរង់មិនសូវត្រង់ទេ និងមាននិន្នាការផលិតនូវពកឈើ។ ដោយឋិតនៅក្នុងអំបូរសិម្ពិកូល ដើមក្រញូងមានលទ្ធភាពផ្តល់ជាតិអាសូតដល់ដី ដូច្នេះគេអាចដាំតាមរបៀបកសិ-រុក្ខកម្ម និងដាំសំរាប់កែប្រែដីឱ្យល្អប្រសើរឡើង។ គេនិយមប្រើឈើក្រញូងជាគ្រឿងសំណង់ គ្រឿងចម្លាក់ គ្រឿងសង្ហារឹមដែលមានគុណភាពប្រណីត តុ ទូ ឧបករណ៍ភ្លេង វត្ថុសិល្បៈ ម៉ាស៊ីនដេរ កាំរទេះ ជាដើម។ ជាឈើមានតំលៃសេដ្ឋកិច្ចខ្ពស់ទាំងទីផ្សារក្នុងស្រុក ក៏ដូចជាសំរាប់នាំចេញ។ ក្រៅពីសាច់ឈើ ឫសរបស់វាក៏អាចប្រើប្រាស់ធ្វើជាគ្រឿងចម្លាក់ដោយដៃបានល្អដែរ។ បច្ចុប្បន្នប្រភេទនេះកំពុងស្ថិតក្នុងស្ថានភាពរងការគំរាមកំហែងយ៉ាងខ្លាំង ហើយអាចឈានទៅរកការបាត់បង់អស់ពីព្រៃធម្មជាតិបើយើងពុំមានវិធានការសង្គ្រោះអោយទាន់ពេលវេលាទេ។


គ្រឿងសង្ហារឹមធ្វើពីឈើក្រញូង

## ៤- លក្ខណៈរុក្ខសាស្ត្រ

**-ដើម:** ជាដើមឈើធំ មានស្លឹកពណ៌បៃតងជានិច្ច និង មានមែកសាខាច្រើន។ ដើមឈើមានកំពស់ ២៥-៣០ម និងមានអង្កត់ផ្ចិតជាមធ្យម ៦០ស.ម ជួនកាលអាចដល់ ១២០ស.ម។ សំបកពណ៌លឿងត្នោត-ព្រឿងៗ និងមានស្នាមប្រេះតូចៗតាមបណ្តោយនៃដើម ជួនកាលរបើកសំបកចេញដោយផ្ទៃក។

**-ស្លឹក:** កន្សោមស្លឹកមានរាងដូចស្វែរ។ ស្លឹកសមាសស្លាបសេសដុះឆ្លាស់គ្នាដែលមានប្រវែង ១៥-២០ស.ម។ កូនស្លឹកមានពី ៧-៩ ក្រាស់ដូចស្បែកហើយស្លឹកដែលនៅខាងចុងមានទំហំធំជាងគេ។ កូនស្លឹកនីមួយៗមានរាងពងក្រពើមូលទ្រវែងដែលដុះឆ្លាស់គ្នា ឬ ដុះឈមបន្ទាប់គ្នា ដែលមានផ្ទៃកខាងចុងទាល់ ឬ មានចុងស្រួចហើយខ្លី។

**-ផ្កា:** ជាចង្កោម ឬ កួរ ដុះចេញពីក្លៀកនៃទងស្លឹក ផ្កាមានពណ៌ស។ ទំរត្របកផ្កាមាន ៥ ដែលឆែកនៅខាងចុងកំពូលហើយគ្មានរោម។ ត្របកផ្កាត្រង់មានរាងដូចក្រញ៉ាំជើងសត្វ ជាធម្មតាមានរាងបួនជ្រុងទ្រវែង កេសរឈ្មោលមានចំនួន៩។

**-ផ្លែ:** ផ្លែវែងហើយរួមតូចខាងចុង សំបកផ្លែរាងសំប៉ែត មិនប្រេះ មានប្រវែងពី ៥-៦ស.ម ទទឹង ១ស.ម។ ក្នុងមួយផ្លែមានគ្រាប់ពី ១-៣ ហើយភាគច្រើនមានមួយគ្រាប់។

**-គ្រាប់:** គ្រាប់សំប៉ែតមានពណ៌ប្រផេះ ឬត្នោត ហើយមានទំហំ ៤មx៧ម.ម។ ក្នុងមួយគីឡូក្រាមមានប្រហែល ៣៥ ០០០គ្រាប់។




## ៥- រដូវចេញផ្កា ផ្លែ

ប្រភេទឈើក្រញូងអាចចេញផ្កា ផ្លែចាប់ពីអាយុ ១៥-៣៥ឆ្នាំ គឺក្នុងកំឡុងពេលដែលធំពេញរូបរាង។ ក្នុងអាយុនេះដើមឈើមានទំហំអង្កត់ផ្ចិតចាប់ពី ២០-៣០ស.ម ។ នៅកម្ពុជាក្រញូងចេញផ្កាផ្លែក្នុងខែ ឧសភា-មិថុនា

ផ្លែទុំនៅខែតុលា-ធ្នូ ។ នៅប្រទេសវៀតណាមក្រញូងចេញផ្កានៅក្នុងខែឧសភា-មិថុនា និងផ្លែទុំក្នុងខែកញ្ញា-វិច្ឆិកា ចំណែកនៅប្រទេសឡាវ ផ្លែក្រញូងចាប់ផ្តើមទុំនៅដើមរដូវក្តៅ (ពីខែធ្នូ-មករា) ។

## ៦- ការបេះប្រមូលគ្រាប់ពូជ

គ្រាប់ទុំនៅពេលណាដែលសំបកផ្លែ បានផ្លាស់ប្តូរពណ៌ទៅជាត្នោតចាស់ ។ នៅប្រទេសឡាវជាញឹកញាប់ ផ្លែក្រញូងត្រូវបានប្រមូលយ៉ាងឆាប់រហ័ស នៅពេលកន្សោមផ្លែចាប់ផ្តើមប្រែពណ៌ពីខៀវខ្ចីទៅពណ៌លឿង ។ ក្នុងពេលវេលានោះក៏រិតបំផ្លាញដោយសត្វល្អិតមានតិចបំផុត ។ ការប្រមូលគ្រាប់អាចធ្វើដោយការក្រាលក្រណាត់កៅស៊ូក្រោមដើម ហើយអង្រួន ឬ កាត់មែកតូចៗទម្លាក់ ។ បន្ទាប់ពីប្រមូលផ្លែបានត្រូវហាលថ្ងៃចំនួន៣ថ្ងៃ ។ សំបកផ្លែស្ងួតមិនប្រេះជំរុះគ្រាប់ចេញទេ លុះត្រាតែបុក ឬវាយកំទេចសំបកផ្លែរួចបក់ រោយសំអាតទើបអាចយកគ្រាប់ចេញបាន ។ គ្រាប់ក្រញូងជាប្រភេទគ្រាប់ដែលអាចរក្សាទុកបានយូរ (Orthodox) ទោះជាយ៉ាងនេះក្តីគ្រាប់ពូជគួរស្តុកទុកនៅកន្លែងស្ងួតជាការល្អ ។ នៅឆ្នាំ២០០៣ គំរោងគ្រាប់ឈើកម្ពុជាបានបេះគ្រាប់ក្រញូងពីឧទ្យានជាតិគីរីរម្យ និង ពីក្នុងប្រភពគ្រាប់ពូជឈើក្នុងព្រៃធម្មជាតិស្ថិតក្នុងខេត្តសៀមរាបយកទៅបណ្តុះនៅថ្នាលបណ្តុះកូនឈើបាក់ស្នាសំរាប់ដាំបង្កើតជាតំបន់ផលិតគ្រាប់ពូជ (Seed Production Area) ។

## ៧- ការបណ្តុះគ្រាប់ពូជ

របៀបប្រព្រឹត្តិកម្មគ្រាប់ដែលគេនិយមប្រើគឺ ត្រាំក្នុងទឹកពុះរយៈពេល ៥នាទី និង បន្ទាប់មកស្រង់វាចេញយកទៅត្រាំក្នុងទឹកត្រជាក់រយៈពេលមួយយប់ទើបយកគ្រាប់នោះទៅសាបក្នុងថ្នាល ឬក៏បណ្តុះក្នុងស្បោងដែលច្រកដីស្រាប់ ។ ក្រៅពីការបន្តពូជដោយគ្រាប់ ក្រញូងអាចបន្តពូជដោយសរីរាង្គផ្សេងទៀតដូចជា ការកាត់មែក និង បំបៅ ។ ក្រៅពីនេះគេធ្លាប់ឃើញជាញឹកញាប់នូវការបន្តពូជតាមខ្នែងគល់ និងខ្នែងឫស ។ ចំការឈើក្រញូងអាចបង្កើតបានតាមរយៈការដុះដោយធម្មជាតិ ឬ បង្កើតដោយដាំតែម្តង ។

## ៨- ការផលិតកូនឈើ

កូនក្រញូងដុះលូតលាស់យឺត បើធៀបនឹងកូនគគីរ ឬផ្ចឿក ។ កូនឈើអាយុ ១៨-២៤ខែ ទើបអាចយកទៅដាំបាន ។




## ៩- ការដាំកូនឈើ

ដើមរដូវភ្លៀងជាពេលវេលាដ៏ល្អបំផុតក្នុងការយកកូនក្រញូងទៅដាំ ហើយត្រូវដាំក្នុងចន្លោះពីគ្នា ៤ម x ៤ម ទើបកូនឈើក្រញូងលូតលាស់ និងផ្តល់គុណភាពឈើបានល្អ ។ ក្នុងគំលាតនេះ គេអាចដាំដំណាំផ្សេងៗទៀតបាននៅចន្លោះជួរកូនឈើតាមរបៀបកសិ-រុក្ខកម្ម ។

## ១០- ឯកសារយោង


- ឃឹម ឃុំ, ១៩៩៦: វិភាគទានលើការសិក្សាពីឈើក្រញូង ។ សារណាបញ្ចប់ការសិក្សា ។ សាកលវិទ្យាល័យភូមិន្ទកសិកម្ម ។
- ឌី ផុន, ២០០០ : វចនានុក្រមរុក្ខជាតិប្រើប្រាស់ក្នុងប្រទេសកម្ពុជា ។
- Anonymous, 1996. Forest Inventory and Planning Institute. Vietnam Forest Trees, Page 453. Agriculture Publishing House, Hanoi.
- Anonymous, 2000. The Names of Forest Plants in Vietnam. Ministry of Agriculture and Rural Development. Department of Science Technology and Product Quality. Agriculture Publishing House, Hanoi.
- CTSP, 2002. Distribution of Selected Tree Species for Gene Conservation in Cambodia.
- Joeker D., 2000. SEED LEAFLET No. 26, Danida Forest Seed Centre.


**បោះពុម្ពលើកទី ១ ឆ្នាំ ២០០៣ ចំនួន ២ ០០០ ច្បាប់**


**រដ្ឋបាលព្រៃឈើ**

**គំរោងគ្រាប់ពូជឈើកម្ពុជា**

DANIDA

អាគារលេខ ៤០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ

ទូរស័ព្ទ: ០២៣ ២១៥ ០៣៤ Email: ctsp@online.com.kh




# ក្រញូង

*Dalbergia cochinchinensis* Pierre